ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ : .១៥....សកបយ.

ប្រញាប់

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់ សហព័ន្ធសហជីព សហជីព កម្មករ និយោជិត សមាគមនិយោជក និយោជកនៃរោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០០០ គណៈកម្មការប្រឹក្សាការងារដែលមានតំណាងមកពីខាងរាជរដ្ឋាភិបាល តំណាងមកពីខាង សហព័ន្ធសហជីព កម្មករ និយោជិត តំណាងមកពីខាងសមាគមនិយោជកបានធ្វើការប្រជុំពិភាក្សាគ្នាអំពីប្រាក់ឈ្នួលអប្បបរមារបស់ កម្មករនិយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង ។ ការប្រជុំនោះ បានប្រព្រឹត្តទៅដោយការពិភាក្សាគ្នាយ៉ាងតឹងតែង ដែលភាគីទាំងអស់បានលើកឡើងនូវទឡ្ហីករណ៍បញ្ជាក់រៀង១ខ្លួន ។ ចំពោះភាគីខាងសមាគមនិយោជកបន្ទាប់ពីលើកហេតុផលសព្វគ្រប់បញ្ជាក់ពីការលំបាករបស់ខ្លួននាពេលបច្ចុប្បន្នបានស្នើឡើងនូវដំណោះស្រាយដូចតទៅ ÷

-ស្នើរក្សាប្រាក់ឈ្នួលអប្បបរមាត្រឹម ៤០ ដុល្លារ ក្នុង ១ ខែ នេះ មួយរយៈពេលទៀតសិន ។

-ផ្តល់ប្រាក់រង្វាន់សំរាប់ការងារទៀងទាត់ចំនួនយ៉ាងតិច ៥ ដុល្លារក្នុង១ខែ ។

-តម្លើងប្រាក់ឈ្នួលស្មើនិង ៥ % នៃប្រាក់ឈ្នួលមូលដ្ឋានចំពោះកម្មករ និយោជិត ដែលមានអតីតភាពការងារ ២ ឆ្នាំ ៦%ចំពោះកម្មករ ដែលមានអតីតភាពការងារលើសពី ៤ ឆ្នាំ ៧%ចំពោះកម្មករដែលមានអតីតភាពការងារលើសពី ៦ ឆ្នាំ ។ល ។

លោកជា វិជ្ជា ប្រធានសហជីព សេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា មិនឯកភាពទទួលយកដំណោះស្រាយរបស់សមាគមនិយោជកដូចខាងលើនេះទេ ។

លោកប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាស្នើសុំតម្លើងប្រាក់ឈ្នួលកម្មករ និយោជិតអោយបាន៦០ដុល្លារក្នុងមួយខែ ។ សហព័ន្ធសហជីពដទៃទៀតរបស់កម្មករ និយោជិតមិនទាន់បានឯកភាពគ្នាលើទឡ្ហីករណ៍ ដែលលើកឡើងដោយតំណាងសហជីព សេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាទេ ព្រោះគ្មានឯកសារ និងមូលដ្ឋានច្បាស់លាស់ ។ ហើយតំណាងសហព័ន្ធ សហជីពចំនួន ៣ ដែលបានចូលរួមប្រជុំក្នុង

ឱកាសនោះបានលើកសំណើសុំពន្យាពេលនៃការប្រជុំនេះទៅថ្ងៃក្រោយទៀត ដើម្បីទុកពេលអោយសហជីព ទាំងអស់ពិគ្រោះគ្នាឡើងវិញ អំពីបញ្ហានេះអោយមានឯកសារ និងមូលដ្ឋានច្បាស់លាស់ទើបដាក់ជូនអង្គប្រជុំ នៃគណៈកម្មការប្រឹក្សាការងារពិនិត្យម្តងទៀត ។ ដោយមានសំណើបីខុសៗគ្នាយ៉ាងនេះ គណៈកម្មការ ប្រឹក្សាការងារ បានធ្វើការអនុម័តលើសំណើទាំងនោះ មួយម្តងៗដើម្បី សំរេចថា ត្រូវយកតាមសំណើណា ។ លទ្ធផលនៃការអនុម័តមានដូចតទៅ ÷

១-អនុម័ត ១១ សំលេងលើ ១៨ សំលេង ដែលបានចូលរួមប្រជុំ ចំពោះសំណើពន្យាពេលប្រជុំរបស់ គណៈកម្មការ ដើម្បីទុកពេលអោយសហព័ន្ធ សហជីពទាំងអស់ពិភាក្សាគ្នាអោយបានឯកភាព ព្រមទាំងមាន ឯកសារ និងមូលដ្ឋានច្បាស់លាស់ ។

២-អនុម័ត ៦ សំលេងលើ ១៨ សំលេង ដែលបានចូលរួមប្រជុំ ចំពោះសំណើរបស់តំណាងសមាគម និយោជក ។

៣-អនុម័ត ១ សំលេងលើ ១៨ សំលេង ដែលបានចូលរួមប្រជុំ ចំពោះសំណើរបស់តំណាងសហជីព សេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។

ផ្អែកតាមលទ្ធផលខាងលើគឺគណៈកម្មការប្រឹក្សាការងារ បានសំរេចពន្យាពេល នៃការប្រជុំរបស់ខ្លួន លើបញ្ហាប្រាក់ឈ្នួលអប្បបរមា នេះលុះដល់ពេលដែល សហព័ន្ធ សហជីពទាំងអស់ពិគ្រោះពិភាក្សាគ្នាបានឯក ភាពហើយលើកសំណើជាថ្មីជូនគណៈកម្មការ ។ អាស្រ័យហេតុនេះគោលការណ៍ដែលកំពុងអនុវត្តជាធរមាន សព្វថ្ងៃត្រូវបន្ត អនុវត្តទៅមួយរយៈពេលទៀត ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគណៈកម្មការប្រឹក្សាការងារ នឹងបន្តខិតខំបំពេញនូវភារៈកិច្ចរបស់ខ្លួនអោយស្របតាមតួនាទីដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋ ពិសេសគឺ ច្បាប់ស្តីពីការងារសំដៅថែរក្សាផលប្រយោជន៍សមស្របយុត្តិធម៌នៃរាល់ភាគីពាក់ព័ន្ធអោយកាន់តែល្អប្រសើរ ឡើងជាលំដាប់ ។

សូមបងប្អូនកម្មករ និយោជិត ទាំងអស់មេត្តាបន្តអនុវត្តការងារ របស់ខ្លួនជាធម្មតាក្នុងស្មារតីនឹងន និងទទួលខុសត្រូវអោយសមស្របជាពលរដ្ឋដ៏ល្អ នៃព្រះរាជាណាចក្រកម្ពុជា ។ សូមបងប្អូនជៀសវាងការ

ប្រព្រឹត្តិអំពើមិនគប្បី ឬអំពើផ្ទុយនិងច្បាប់រដ្ឋនានាដែលអាចនាំមកនូវផលវិបាកមិនល្អដល់ខ្លួនយើងផង និងដល់សង្គមជាតិរបស់យើងផង ។ ៸

ភ្នំពេញ. ថ្ងៃទី ២២ ខែ ០៧ ឆ្នាំ២០០០

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

<u>ចម្លងជូន:</u>

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ " ដើម្បីជ្រាប "
- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ច ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទារាជធានី-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់សមាគមនិយោជក " ដើម្បីអនុវត្ត"
- គ្រប់សហព័ន្ធ សហជីព "ដើម្បីអនុវត្ត "
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
- កាលប្បវត្តិ និងឯកសារ